

# លេងដេញចាប់ផ្លែឈើ

**នេះគឺជាល្បែងដែលអ្នកអាចលេងជាមួយមិត្តភក្តិ និងគ្រួសារបាន !**

១. គូសសម្គាល់បន្ទាត់ចាប់ផ្ដើម និងបន្ទាត់បញ្ចប់ ។ ជ្រើសរើសមនុស្សម្នាក់ឲ្យធ្វើជាអ្នកដេញតាម ។

២. មនុស្សគ្រប់គ្នាឈរនៅលើបន្ទាត់ចាប់ផ្ដើម ហើយជ្រើសរើសផ្លែឈើមួយដោយសម្ងាត់ ។ អ្នកដេញចាប់ឈរនៅពីក្រោយបន្ទាត់ចាប់ផ្ដើម ដោយបែរខ្នងរបស់ពួកគេដាក់អ្នកលេងផ្សេងទៀត ។

៣. អ្នកដេញចាប់និយាយឈ្មោះផ្លែឈើមួយ ។

៤. អ្នកលេងកាន់ផ្លែឈើរបស់ខ្លួនដែលបានគេជ្រើសហៅនោះ ត្រូវរត់ទៅបន្ទាត់បញ្ចប់ ។ អ្នកដេញចាប់បែរខ្នងមកវិញ ហើយព្យាយាមដេញចាប់ពួកគេនោះ ។

៥. អ្នកណាដែលគេចាប់បាន នឹងធ្វើជាអ្នកដេញចាប់បន្ទាប់ !

## អ្នកធ្វើម្ហូប

នៅក្នុងពាក្យសម្ដីនៃប្រាជ្ញាវាងវៃ ព្រះយេស៊ូវបានមានបន្ទូលប្រាប់យើងពីអាហារណាដែលល្អសម្រាប់បរិភោគ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩:១០–១២,១៤ ។ បន្ទាប់មក សូមគូរមុខម្ហូបដែលអ្នកចូលចិត្តមួយចំនួននៅលើចាននៅខាងក្រោមនេះ !